# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីប្រកាស តែងតាំងមុខតំណែងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត កំពត








នៅរសៀលថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១៤ នៅសាលាខេត្តកំពត មានរៀបចំពិធីប្រកាសតែងតាំងមុខតំណែង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពត ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួម ពីឯកឧត្តម **ខូយ ឃុនហ៊ួរ** អភិបាលនៃគណៈអភិបាលខេត្តកំពត ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម តំណាងអាជ្ញាធរខេត្ត តំណាងមន្ទីរអង្គភាពជុំវិញខេត្ត និងមន្ត្រីរាជការនៃមន្ទីរឧស្សាហកម្មខេត្ត ជាច្រើនរូបទៀត ។

តាមរបាយការណ៍សង្ខេបពីតំណាងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពត បានបញ្ជាក់ថា៖មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពត មានការិយាល័យចំនួន៣ សាខាមជ្ឈមណ្ឌលចំនួន០១ គឺ សាខាមជ្ឈមណ្ឌលមាត្រាសាស្ត្រ និង អង្គភាពចំនួន២៖ គឺអង្គភាពស្រែអំបិល និងរដ្ឋាករទឹក ក្របខ័ណ្ឌមន្ត្រីសរុបក្នុងមន្ទីរ មានចំនួន២២នាក់ ស្រី ០៧ នាក់ ។ ជាមួយនិងការលើកឡើងពីសកម្មភាពការងារ លទ្ធផល និងទិសដៅ របាយការណ៍ក៏បានលើកឡើងពីបញ្ហាប្រឈម ការលំបាក ព្រមទាំងសំណូមពរផងដែរ ។



បន្ទាប់ពីឯកឧត្តម **អ៊ុំ សុថា** នាយកខុទ្ទកាល័យនិងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអានប្រកាសលេខៈ០៩៨ MIH/2014 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្រ្តីរាជការ ដែលបានសម្រេចតែងតាំងលោក **សុខ គីមជឿន** ជាប្រធាមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តកំពត រួចមក លោក **សុខ គីមជឿន** បានឡើងទទួលសេចក្តីប្រកាស ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ព្រមទាំងបានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីឆើយតប និងការផ្តល់ទំនុកចិត្ត របស់ឯកឧត្តម ទេសរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម គណៈអភិបាលខេត្ត និង ក្រុមប្រឹក្សាខេត្ត ដោយបានសន្យា ថាៈនឹងខិតខំប្រមូលនូវកម្លាំងកាយ បញ្ញា ស្មារតី និងបទពិសោធន៍ ដែលមានកន្លងមក ធ្វើជាមូលដ្ឋានក្នុងការសម្រប សម្រួល ចាត់ចែងការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានល្អប្រសើរ ។

ឯកឧត្តម **ខ្ញុយ ឃុនហ៊្វ** អភិបាលនៃគណៈអភិបាលខេត្តកំពត បានឡើងសំដែងការស្វាគមន៍និងអបអរសាទរចំពោះលោក **សុខ គីមជឿន** ដែលត្រូវបានតែតាំងជាប្រធានមន្ទីរថ្មីនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។ ឯកឧត្តម បានបញ្ជាក់ថាៈលោក **សុខ គីមជឿន** ធ្លាប់ជាអនុប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និងជាប្រធានស្តីទីមន្ទីរឧស្សាហកម្ម និងសិប្បកម្ម មានស្នាដៃល្អជាច្រើន ក្នុងការរ៉ាប់រងការងារស្នូល ពិសេសមានកិច្ចសហការល្អជាមួយអជ្ញារធរខេត្ត និងជំនាញពាក់ព័ន្ធ ដើម្បីឆ្លើយតប និងតម្រូវការរបស់ខេត្ត និងប្រជាពលរដ្ឋ ។ ឯកឧត្តម បានផ្តល់ផ្តល់អនុស្សាន៏ដាស់តឿន ឱ្យលោកប្រធានមន្ទីរមានទឹកចិត្តទូលំទូលាយ បន្តរក្សាសាមគ្គីភាពផ្ទៃក្នុងខ្ពស់ និងកិច្ចសហប្រតិបត្តិការល្អជាមួយមន្ទីរអង្គភាពជំនាញជុំវិញខេត្ត និងអជ្ញាធរគ្រប់លំដាប់ថ្នាក់ ។ ជាមួយគ្នានេះ ឯកឧត្តម អភិបាលខេត្ត បានធ្វើការសំណូមពរដល់លោកប្រធានមន្ទីរថ្មី ស្វែងយល់អំពីស្ថានភាព និងបរិយាកាស ទីកន្លែងថ្មី ដើម្បី

មានមូលដ្ឋានសម្របសម្រួលការងារ ឱ្យបានជោគជ័យផ្លែផ្កា ពិសេសស្វែងយល់អំពីបទដ្ឋានគតិយុត្ត និងច្បាប់នានាពាក់ព័ន្ធការងារជំនាញ អនុក្រឹត្យ សារាចររបស់ថ្នាក់ជាតិ ក៏ដូចជាគោលការណ៍ ផែនការជាក់ស្តែង របស់អាជ្ញាធរខេត្ត និងបេសកកម្មចំបងរបស់មន្ទីរជាអាទិ៍:-បន្តផ្សព្វផ្សាយច្បាប់ស្តីការគ្រប់គ្រងរោងចក្រ សហគ្រាស សិប្បកម្ម និងការណែនាំឱ្យម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម យកចិត្តទុកដាក់ការអនុវត្តនូវគុណភាពផលិតផល សុវត្ថិភាពពលកម្ម និងបរិស្ថានឧស្សាហកម្មល្អ-ជម្រុញការសុំច្បាប់បើកមូលដ្ឋានរោងចក្រ សិប្បកម្ម និងការចុះបញ្ជីមូលដ្ឋានផលិតកម្ម-ផ្សព្វផ្សាយច្បាប់ស្តីពីស្តង់ដារឱ្យបា នទូលំទូលាយ និងណែនាំ បំពាក់បំប៉នជំនាញបច្ចេកទេសដល់មន្ត្រី និងរួមសហការជាមួយអង្គភាពជាដៃគូឱ្យបានល្អប្រសើរ

ឯកឧត្តម ទេស រដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញមានមតិសំណេះសំណាល ដោយបាន សំដែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការដឹកនាំរបស់អជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ធ្វើឱ្យខេត្តកំពតមាន ការរីកចម្រើនប្រែមុខមាត់ថ្មីសមជាខេត្តទេសចរណ៍ ដែលមានមាត់សមុទ្រ ឆ្នេរខ្សាច់កោះ និងព្រៃភ្នំដ៏ស្រស់ត្រកាល។ ឯកឧត្តម បានអបអរសាទរចំពោះលោក **សុខ គឹមជឿន** ដែលត្រូវបានប្រគល់ភារកិច្ចថ្មី ជាប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពត ដោយលោក គឺជាមន្ត្រី នៅទីនេះស្រាប់ មានបទពិសោធន៍យូរឆ្នាំ សង្ឃឹមថា:កិច្ចការគ្រប់គ្រង ដឹកនាំមន្ទីរមានដំណើរការកាន់តែល្អប្រសើរ និងមាន ភាពរលូនទៅមុខ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា:ថ្វីត្បិតតែក្រសួងឧស្សាហកម្ម និង សិប្បកម្ម បង្កើតឡើងនៅ លើមូលដ្ឋាននៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាក្រសួងចាស់ស្រាប់ ប៉ុន្តែតម្រូវឱ្យមានការរៀបចំជាថ្មីនូវច្បាប់ អនុក្រឹត្យ ដែលកំណត់ឡើងវិញនូវមុខងារ ភារកិច្ច បេសកកម្មព្រមទាំង ចាំបាច់ត្រូវកែសម្រួលរចនាសម្ព័ន្ធឡើងវិញដែរ (រាប់ទាំងឈ្មោះមន្ទីរ និងត្រាមូល) ។ ដូច្នេះ ត្រូវមានការតែងតាំងជាថ្មី មានលក្ខណ: ព្រមៗគ្នានូវប្រធានមន្ទីរគ្រប់ខេត្ត ទូទាំងប្រទេសសម្រាប់អណត្តិការងារថ្មីនេះ ។ ទន្ទឹមនឹងរៀបចំតួនាទី ភារកិច្ចរបស់ នាយកដ្ឋាននានា ក្រសួងកំពុងរៀបចំ ប្រកាសថ្មីសម្រាប់ដំណើរការការងាររបស់មន្ទីរ ដោយគ្រោងឱ្យមាន ការិយាល័យ ចំនួន០៤ ចំណុះមន្ទីរគឺ:**១**-ការិយាល័យ កិច្ចការទូទៅ **២**-ការិយាល័យកិច្ចការឧស្សាហកម្ម **៣**-ការិយាល័យ ស្តង់ដារ និងមាត្រាសាស្ត្រ និង **៤**-ការិយាល័យ ទឹកស្អាត ។ ទាក់ទង និងការយាល័យជំនាញខាងលើ ដូចជា:ការិយាល័យ ស្តង់ដារ និងមាត្រាសាស្ត្រ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានរំលឹកថា:ការិយាល័យនេះ ត្រូវមានកិច្ចការងារច្រើនក្នុងការចុះត្រួតពិនិត្យនូវឧបករណ៍រង្វាស់រង្វាល់ ដូចជា:កុងទ័រទឹក-ជញ្ជីញថ្លឹង-ពិនិត្យសុក្រឹតភាពនៃចំណុះប្រេងសាំងតាមស្ថានីយ៍ប្រេង នានា និងពិនិត្យការគោរពស្តង់ដាម្ហូបអាហារជាដើម ។ ជាមួយគ្នានេះ ការិយាល័យឧស្សាហកម្ម ក៏មានភារកិច្ចការចុះពិនិត្យ ជាក់ស្តែងដល់ទីតាំងរោងចក្រ និងការចុះបញ្ជីឱ្យអស់នូវសហគ្រាសខ្នាតតូច និងមធ្យម ដែលមានជាច្រើនមូលដ្ឋានក្នុងទូទាំងខេត្ត ដើម្បីឱ្យសហគ្រិនទាំងអស់នោះ ក្លាយជានីតិបុគ្គល និងងាយស្រួល ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ ។ ដោយ ឡែកទាក់ទង និងការងារទឹកស្អាត ឯកឧត្តម ទេសរដ្ឋ មន្ត្រីបានបញ្ជាក់ថា:ខេត្តកំពតមានស្ថានីយ៍ផលិតទឹកស្អាតទាំងរដ្ឋ និងឯកជន ។ ឯកឧត្តម បានស្នើឱ្យមានការយកចិត្តទុកដាក់ចំពោះការពង្រីកបណ្តាញចែកចាយ និងមានប្រព័ន្ធគ្រប់គ្រងល្អប្រសើរ ជាពិសេសប្រកាន់នូវគោលការណ៍ ០៤ យ៉ាង គឺ: គុណភាព-សុវត្ថិភាព-និរន្តរភាព និងតម្លៃ

សមរម្យ ។ ទាក់ទងនិងការងារស្រែអំបិល ឯកឧត្តម បានបង្ហាញនូវកង្វល់ និងស្នើឱ្យមានការយកចិត្តទុកដាក់លើបញ្ហាគ្រប់គ្រងស្រែអំបិលឱ្យបានហ្មត់ចត់ ជាពិសេសគឺផ្ទៃដីស្រែអំបិល ក្នុងសហគមន៍អ្នកផលិតអំបិលខេត្តកំពត និងកែប ដោយមិនត្រូវបោះបង់ការផលិត រឺកែប្រែប្រភេទដីទៅជាមុខសញ្ញាអាជីវកម្មផ្សេងឡើយ ហើយក្រសួងនឹងចុះពិនិត្យស្វែងយល់និងវាយតម្លៃពីការគ្រប់គ្រងរបស់សហគមន៍ស្រែអំបិលនៅពេលខាងមុខ ។ ចំពោះបញ្ហាកំពុងជួបការលំបាក និងមានសំណូមពរមានដូចជាៈបញ្ហាធុនធានមនុស្ស និងកង្វះមន្ត្រីរាជការ-ទីកន្លែងធ្វើការ-ថវិការដំណើរការ និងការបំពាក់សម្ភារៈជាដើម ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានទទួលស្គាល់ថាៈពិតជាមានការលំបាក ក្នុងពេលដែលយើងបំបែកមន្ទីរចាស់មួយទៅជាមន្ទីរថ្មីពីរ ។ ទោះជាយ៉ាងណាក្រសួងនឹងខិតខំ រិៈរកមធ្យោបាយ ដោះស្រាយការលំបាកនេះជាបណ្តើរៗ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានស្នើឱ្យឯកឧត្តម អភិបាលខេត្ត ពិនិត្យមើលគុណសម្បិត្តិមន្ត្រីក្នុងខេត្តដើម្បី ធ្វើការតែងតាំងបំពេញប្រអប់ដែលខ្វះ ដូចជាៈអនុប្រធានមន្ទីរ-ប្រធានការិយាល័យ និងអនុការិយាល័យជាដើម ដើម្បីបញ្ជូនមក ឯកឧត្តម ចុះហត្ថលេខា តែងតាំង ឱ្យបានឆាប់រហ័ស ។



បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ឯកឧត្តមអភិបាលខេត្ត និង ប្រតិភូអមដំណើរបានអញ្ជើញចុះពិនិត្យមើលទីតាំងស្ថានីយ៍រដ្ឋាករទឹកខេត្តកំពត និងជួបសំណេះសំណាលជាមួយមន្ត្រី មន្ទីរឧស្សាហកម្ម ខេត្តកំពត ព្រមទាំងឧបត្ថម្ភថវិការមួយចំនួនផងដែរ ។





